01381719

E443/9.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧

ជូនចំពោះសាស្ត្រាចារ្យ Heynowski

**កម្មវត្ថុ៖ លិខិតថ្លែងអំណរគុណចំពោះការប្រគល់ឯកសារ**

តាងនាមឱ្យអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ខ្ញុំសូមថ្លែងអំណរគុណលោកសាស្ត្រាចារ្យដែលបានផ្តល់ឯកសារមក អ.វ.ត.ក នាពេលថ្មីៗនេះ។ ឯកសារទាំងនេះ រួមមាន សៀវភៅកំណត់ត្រាមួយក្បាល កំណត់ត្រាវាយអង្គុលីលេខ និងរូបថតមួយចំនួនពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ ដែលលោកបានរក្សាទុកនៅក្នុងបណ្ណសាររបស់លោកអស់រយៈពេលជាច្រើនឆ្នាំ។

ដោយសារតែឯកសារទាំងនេះមានសារៈសំខាន់ចំពោះប្រវត្តិសាស្ត្រកម្ពុជា ឯកសារទាំងនេះត្រូវបាន ឬ ក្នុងពេលឆាប់ៗនេះនឹងត្រូវប្រគល់ជូនក្នុងនាមលោក ទៅឱ្យសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង មន្ទីរសន្តិសុខ ស-២១ ដើម្បីរក្សាទុក និង/ឬ កែលម្អគុណភាពឯកសារ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះការប្រគល់ឯកសារទាំងនេះត្រឡប់មកប្រទេសកម្ពុជាវិញ ដែលអាចជួយទៅដល់ការស្វែងយល់ការពិតឱ្យកាន់តែប្រសើរជាងមុនទៀតទាក់ទិននឹងមន្ទីរសន្តិសុខ ស-២១។

អង្គជំនុំជម្រះសូមកោតសរសើរយ៉ាងក្រៃលែងចំពោះកិច្ចសហការរបស់លោក។

សូមលោកសាស្ត្រាចារ្យទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧

ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E.C.C.C * C.E.T.C

និល ណុន